- សេចក្តីព្រាងដំបូង ១៧ តុលា ២០២៣
- ប្រជុំថ្ងៃ ៨ ; ១៤ វិច្ឆិកា ២០២៣
- សម្អាតថ្ងៃទី២០ វិច្ឆិកា ឆ្នាំ២០២៣ និងបញ្ចូលខ្លឹមសារអាជ្ញាបណ្ណ (១៩ ធ្នូ ២០២៣)
- ប្រជុំថ្ងៃទី២២ ; ២៥ ; ២៧ និង ២៨ ធ្នូ ២០២៣
- ប្រជុំថ្ងៃទី២ ៤ ៥ ១៦ និង ២៩ មករា ២០២៤
- ប្រជុំថ្ងៃ ១៤ និង ២៣ កុម្ភៈ ២០២៤
- **សរុបប្រជុំ ១៣ លើក**

# សេចក្តីព្រាងអនុក្រឹត្យ
# ស្តីពី
# ការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១._**

អនុក្រឹត្យនេះកំណត់អំពីបទល្មើស និងទឹកប្រាក់ពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្ដីពីគណនេយ្យនិងសវនកម្ម ព្រមទាំងកំណត់អំពីវិធានការ និងយន្តការនៃការពិន័យនិងការគ្រប់គ្រងពិន័យអន្តរការណ៍ ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់នេះ។

**មាត្រា២._**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះ ÷

- សហគ្រាសរងសវនកម្ម និងសហគ្រាសមិនរងសវនកម្ម ឬនីតិបុគ្គលដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និង/ឬនៅអគ្គនាយកដ្ឋានពន្ធដារ ដែលជាសហគ្រាសអ្នកជាប់ពន្ធធំនិងសហគ្រាសអ្នកជាប់ពន្ធមធ្យម និងគ្រប់អង្គភាពមិនស្វែងរកប្រាក់ចំណេញដែលបានចុះបញ្ជីនៅក្រសួងស្ថាប័នមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់គណនេយ្យករ និងសវនករដែលជាសមាជិករបស់វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា និងទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬសវនកម្មពីនិយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**)។

**មាត្រា៣._**

ក្នុងក្របខណ្ឌនៃអនុក្រឹត្យនេះ វាក្យស័ព្ទមួយចំនួនដែលយកមកប្រើត្រូវបានកំណត់និយមន័យដូចតទៅ÷

- **ការមិនកាន់បញ្ជីគណនេយ្យ** សំដៅដល់ការមិនបានរៀបចំឯកសារគណនេយ្យ ឬការមិនកត់ត្រាប្រតិបត្តិការទាំងនោះចូលទៅក្នុងសៀវភៅ ឬបញ្ជីគណនេយ្យដែលបានកំណត់ក្នុងច្បាប់ស្ដីពីគណនេយ្យនិងសវនកម្ម និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- **ការកាន់បញ្ជីគណនេយ្យមិនត្រឹមត្រូវ** សំដៅដល់÷
  - ១- ឯកសារគាំទ្រគណនេយ្យមិនមានព័ត៌មានគ្រប់គ្រាន់ និងខ្វះការអាចទុកចិត្តបាន ក្នុងការគាំទ្រអត្ថិភាព ភាពពេញលេញ និងភាពត្រឹមត្រូវនៃប្រតិបត្តិការ ព្រមទាំងព្រឹត្តិការណ៍ និងលក្ខខណ្ឌដទៃទៀតដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ឬ
  - ២- ការរៀបចំបញ្ជីគណនេយ្យមិនស្របតាមស្តង់ដាគណនេយ្យជាធរមាន ឬមិនមានភាពពេញលេញ ត្រឹមត្រូវ អាចទុកចិត្តបាន ទាន់ពេល និងមិនអាចផ្ទៀងផ្ទាត់ទៅនឹងឯកសារគាំទ្រគណនេយ្យ ឬរបាយការណ៍ហិរញ្ញវត្ថុបាន។
- **ការត្រួតពិនិត្យដល់ទីកន្លែង** សំដៅដល់ការត្រួតពិនិត្យដល់អាស័យដ្ឋានគោលរបស់សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ។
- **ការត្រួតពិនិត្យលើឯកសារ** សំដៅដល់ការត្រួតពិនិត្យលើបញ្ជីការគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ និងគណនេយ្យករ ឬសវនករ។
- **គណនេយ្យករ ឬសវនករជានីតិបុគ្គល** សំដៅដល់ក្រុមហ៊ុនគណនេយ្យ ឬក្រុមហ៊ុនសវនកម្មដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពី **ន.គ.ស.**។

- **គណនេយ្យករ ឬសវនករជារូបវន្តបុគ្គល** សំដៅដល់សមាជិកជារូបវន្តបុគ្គលរបស់វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជាដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពី **ន.គ.ស.**។
- **បុគ្គលល្មើស** សំដៅដល់សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬគណនេយ្យករ ឬសវនករដែលប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។
- **ម្ចាស់អាជ្ញាបណ្ណ** សំដៅដល់បុគ្គលដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬសវនកម្មពី **ន.គ.ស.**។
- **របាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន** សំដៅដល់របាយការណ៍ហិរញ្ញវត្ថុដែលអនុលោមតាមលក្ខខណ្ឌចាំបាច់នានានៃស្តង់ដាគណនេយ្យសម្រាប់ ការទទួលស្គាល់ ការឈប់ទទួលស្គាល់ ការវាស់វែង ការដាក់បង្ហាញ និងការលាតត្រដាងព័ត៌មាន ដែលអនុវត្តចំពោះប្រតិបត្តិការ ព្រមទាំងព្រឹត្តិការណ៍ និងលក្ខខណ្ឌដទៃទៀត។
- **សហគ្រាសមិនរងសវនកម្ម** សំដៅដល់សហគ្រាសដែលមិនស្ថិតក្នុងលក្ខខណ្ឌត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឱ្យរងសវនកម្មឯករាជ្យ។
- **សហគ្រាសរងសវនកម្ម** សំដៅដល់សហគ្រាសដែលស្ថិតក្នុងលក្ខខណ្ឌត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឱ្យរងសវនកម្មឯករាជ្យ ដែលលក្ខខណ្ឌនោះត្រូវបានកំណត់ដោយបទប្បញ្ញត្តិជាធរមាន។
- **អង្គភាពមិនស្វែងរកប្រាក់ចំណេញមិនរងសវនកម្ម** សំដៅដល់អង្គភាពមិនស្វែងរកប្រាក់ចំណេញដែលមិនស្ថិតក្នុងលក្ខខណ្ឌត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឱ្យរងសវនកម្មឯករាជ្យ។
- **អង្គភាពមិនស្វែងរកប្រាក់ចំណេញរងសវនកម្ម** សំដៅដល់អង្គភាពមិនស្វែងរកប្រាក់ចំណេញដែលស្ថិតក្នុងលក្ខខណ្ឌត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឱ្យរងសវនកម្មឯករាជ្យ ដែលលក្ខខណ្ឌនោះត្រូវបានកំណត់ដោយបទប្បញ្ញត្តិជាធរមាន។
- **អំពើរាំងស្ទះ** សំដៅដល់ការប្រព្រឹត្តនូវអំពើណាមួយដោយបុគ្គលល្មើស រួមមាន÷
  ១- ពុំបានផ្តល់កិច្ចសហការជាមួយមន្រ្តីនៃ **ន.គ.ស.** ដែលកំពុងអនុវត្តភារកិច្ច ឬ
  ២- មិនអនុញ្ញាតឱ្យ **ន.គ.ស.** ធ្វើការពិនិត្យបញ្ជីគណនេយ្យ ឬឯកសារគណនេយ្យផ្សេងៗ ឬ
  ៣- កសាង ឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានមិនត្រឹមត្រូវផ្សេងៗពាក់ព័ន្ធគណនេយ្យ ឬ
  ៤- មិនបានជូនដំណឹងទៅ**ន.គ.ស.** អំពីការផ្លាស់ប្តូរព័ត៌មានដែលបានចុះបញ្ជីរួច ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី២
## បទល្មើស និងពិន័យអន្តរការណ៍
### ផ្នែកទី១
### ចំពោះសហគ្រាស

**មាត្រា៤._**

សហគ្រាសរងសវនកម្ម ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ចំពោះបទល្មើសដូចខាងក្រោម÷

១- ការយឺតយ៉ាវក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.** តាមពេលកំណត់ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ២៥០.០០០ (ពីររយហាសិបពាន់) រៀលក្នុង១ថ្ងៃ។

២- ការមិនដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.** តាមពេលកំណត់ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៤០.០០០.០០០ (សែសិបលាន)រៀល។

៣- ការមិនដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យ តាមលក្ខខណ្ឌកំណត់ដោយបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៦០.០០០.០០០ (ហុកសិបលាន)រៀល។

៤- ការមិនកាន់បញ្ជីគណនេយ្យ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៤០.០០០.០០០(សែសិបលាន)រៀល។

៥- ការកាន់បញ្ជីគណនេយ្យមិនត្រឹមត្រូវ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ២០.០០០.០០០(ម្ភៃលាន)រៀល។

៦- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនស្របតាមស្តង់ដាគណនេយ្យជាធរមាន ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន)រៀល។

៧- ការមិនប្រើប្រាក់រៀលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ២.០០០.០០០ (ពីរលាន)រៀល។

៨- ការមិនប្រើភាសាខ្មែរនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ២.០០០.០០០ (ពីរលាន)រៀល។

៩- ការប្រើកិរិយបរិច្ឆេទគណនេយ្យខុសពីការកំណត់នៅក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ដោយគ្មានការអនុញ្ញាតជាមុនពី **ន.គ.ស.** ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ២០.០០០(ម្ភៃពាន់)រៀលក្នុង១ថ្ងៃ។

១០- ការមិនប្រើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន)រៀល។

១១- ការមិនរក្សាទុកឯកសារគណនេយ្យស្របតាមពេលវេលាកំណត់ដោយច្បាប់ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន)រៀល។

១២- ការប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិគណនេយ្យនិងសវនកម្ម ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន)រៀល។

១៣- ការក្លែងបន្លំឯកសារគណនេយ្យ បញ្ជីគណនេយ្យ ឬក្លែងបន្លំរបាយការណ៍ហិរញ្ញវត្ថុត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន)រៀល ដោយមិនទាន់គិតអំពីទោសទណ្ឌដែលកំណត់នៅក្នុងច្បាប់ ឬបទប្បញ្ញត្តិជាធរមានដទៃទៀត។

**មាត្រា៥._**

សហគ្រាសមិនរងសវនកម្ម ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ចំពោះបទល្មើសដូចខាងក្រោម÷

១- ការយឺតយ៉ាវក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.** តាមពេលកំណត់ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ២០០.០០០ (ពីររយពាន់)រៀលក្នុង១ថ្ងៃ។

២- ការមិនដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.** តាមពេលកំណត់ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៤០.០០០.០០០ (សែសិបលាន)រៀល។

៣- ការមិនកាន់បញ្ជីគណនេយ្យ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៣០.០០០.០០០(សាមសិបលាន)រៀល។

៤- ការកាន់បញ្ជីគណនេយ្យមិនត្រឹមត្រូវ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល។

៥- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនស្របតាមស្តង់ដាគណនេយ្យជាធរមាន ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៨.០០០.០០០ (ប្រាំបីលាន) រៀល ។

៦- ការមិនប្រើប្រាក់រៀលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ២.០០០.០០០ (ពីរលាន) រៀល។

៧- ការមិនប្រើភាសាខ្មែរនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ២.០០០.០០០ (ពីរលាន) រៀល។

៨- ការប្រើការិយបរិច្ឆេទគណនេយ្យខុសពីការកំណត់នៅក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ដោយគ្មានការអនុញ្ញាតជាមុនពី **ន.គ.ស.** ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ២០.០០០ (ម្ភៃពាន់) រៀលក្នុងមួយថ្ងៃ។

៩- ការមិនប្រើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៨.០០០.០០០ (ប្រាំបីលាន) រៀល។

១០- ការមិនរក្សាទុកឯកសារគណនេយ្យស្របតាមពេលវេលាកំណត់ដោយច្បាប់ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន) រៀល។

១១- ការប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិគណនេយ្យនិងសវនកម្ម ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន) រៀល។

១២- ការក្លែងបន្លំឯកសារគណនេយ្យ បញ្ជីគណនេយ្យ ឬក្លែងបន្លំរបាយការណ៍ហិរញ្ញវត្ថុត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន) រៀល ដោយមិនទាន់គិតអំពីទោសទណ្ឌដែលកំណត់នៅក្នុងច្បាប់ ឬបទប្បញ្ញត្តិជាធរមានដទៃទៀត។

## ផ្នែកទី២
## ចំពោះអង្គភាពមិនស្វែងរកប្រាក់ចំណេញ

**មាត្រា៦._**

អង្គភាពមិនស្វែងរកប្រាក់ចំណេញរងសវនកម្ម ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ចំពោះបទល្មើសដូចខាងក្រោម÷

១- ការយឺតយ៉ាវក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.** តាមពេលកំណត់ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៤០.០០០ (សែសិបពាន់) រៀលក្នុង១(មួយ) ថ្ងៃ។

២- ការមិនដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.** តាមពេលកំណត់ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៨.០០០.០០០ (ប្រាំបីលាន) រៀល។

៣- ការមិនដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យ តាមលក្ខខណ្ឌកំណត់ដោយប្រកាសស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៤.០០០.០០០ (បួនលាន) រៀល។

៤- ការមិនកាន់បញ្ជីគណនេយ្យ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៨.០០០.០០០ (ប្រាំបីលាន) រៀល។

៥- ការកាន់បញ្ជីគណនេយ្យមិនត្រឹមត្រូវ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៤.០០០.០០០ (បួនលាន) រៀល។

៦- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនស្របតាមស្តង់ដាគណនេយ្យជាធរមាន ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ២.០០០.០០០ (ពីរលាន) រៀល។

៧- ការមិនប្រើប្រាក់រៀលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៨០០.០០០ (ប្រាំបីរយពាន់)រៀល។

៨- ការមិនប្រើភាសាខ្មែរនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៨០០.០០០ (ប្រាំបីរយពាន់)រៀល។

៩- ការប្រើកាវិយបរិច្ឆេទគណនេយ្យខុសពីការកំណត់នៅក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ដោយគ្មានការអនុញ្ញាតជាមុនពី **ន.គ.ស.** ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០ (ដប់ពាន់)រៀលក្នុង១ថ្ងៃ។

១០- ការមិនប្រើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ២.០០០.០០០ (ពីរលាន)រៀល។

១១- ការមិនរក្សាទុកឯកសារគណនេយ្យស្របតាមពេលវេលាកំណត់ដោយច្បាប់ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៤.០០០.០០០ (បួនលាន)រៀល។

១២- ការប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិគណនេយ្យនិងសវនកម្ម ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៦.០០០.០០០ (ប្រាំមួយលាន)រៀល។

១៣- ការក្លែងបន្លំឯកសារគណនេយ្យ បញ្ជីគណនេយ្យ ឬក្លែងបន្លំរបាយការណ៍ហិរញ្ញវត្ថុត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៨.០០០.០០០ (ប្រាំបីលាន)រៀល ដោយមិនទាន់គិតអំពីទោសទណ្ឌដែលកំណត់នៅក្នុងច្បាប់ ឬបទប្បញ្ញត្តិជាធរមានដទៃទៀត។

**មាត្រា៧._**

អង្គភាពមិនស្វែងរកប្រាក់ចំណេញមិនរងសវនកម្ម ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ចំពោះបទល្មើសដូចខាងក្រោម÷

១- ការយឺតយ៉ាវក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.** តាមពេលកំណត់ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៣០.០០០ (សាមសិបពាន់)រៀលក្នុងមួយថ្ងៃ។

២- ការមិនដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.** តាមពេលកំណត់ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៨.០០០.០០០ (ប្រាំបីលាន)រៀល។

៣- ការមិនកាន់បញ្ជីគណនេយ្យ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៨.០០០.០០០ (ប្រាំបីលាន)រៀល។

៤- ការកាន់បញ្ជីគណនេយ្យមិនត្រឹមត្រូវ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ២.០០០.០០០ (ពីរលាន)រៀល។

៥- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនស្របតាមស្តង់ដាគណនេយ្យជាធរមាន ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១.០០០.០០០ (មួយលាន)រៀល។

៦- ការមិនប្រើប្រាក់រៀលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៨០០.០០០ (ប្រាំបីរយពាន់)រៀល។

៧- ការមិនប្រើភាសាខ្មែរនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៨០០.០០០ (ប្រាំបីរយពាន់)រៀល។

៨- ការប្រើកាវិយបរិច្ឆេទគណនេយ្យខុសពីច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ដោយគ្មានការអនុញ្ញាតជាមុនពី **ន.គ.ស.** ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០ (ដប់ពាន់)រៀលក្នុងមួយថ្ងៃ។

៩- ការមិនប្រើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១.០០០.០០០ (មួយលាន)រៀល។

១០- ការមិនរក្សាទុកឯកសារគណនេយ្យស្របតាមពេលវេលាកំណត់ដោយច្បាប់ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ២.០០០.០០០ (ពីរលាន)រៀល។

១១- ការប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិគណនេយ្យនិងសវនកម្ម ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៣.០០០.០០០ (បីលាន)រៀល។

១២- ការក្លែងបន្លំឯកសារគណនេយ្យ បញ្ជីគណនេយ្យ ឬក្លែងបន្លំរបាយការណ៍ហិរញ្ញវត្ថុត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៨.០០០.០០០ (ប្រាំបីលាន)រៀល ដោយមិនទាន់គិតអំពីទោសទណ្ឌដែលកំណត់នៅក្នុងច្បាប់ ឬបទប្បញ្ញត្តិជាធរមានដទៃទៀត។

## ផ្នែកទី៣

## ចំពោះគណនេយ្យករ និងសវនករ

**មាត្រា៨._**

គណនេយ្យករជារូបវន្តបុគ្គល ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ចំពោះបទល្មើសដូចខាងក្រោម÷

១- ប្រព្រឹត្តល្មើសទៅនឹងកថាខណ្ឌទី២ នៃមាត្រា២៨ នៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ២០.០០០.០០០ (ម្ភៃលាន)រៀល។

២- ការយឺតយ៉ាវក្នុងការបង់កម្រៃអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យប្រចាំឆ្នាំ តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ម្ចាស់អាជ្ញាបណ្ណត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់២០០.០០០(ពីររយពាន់)រៀលក្នុងមួយថ្ងៃ។

៣- ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យតាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ២០០.០០០(ពីររយពាន់)រៀលក្នុងមួយថ្ងៃ។

៤- ការមិនមានវត្តមានរបស់គណនេយ្យករជាជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា តិចជាងរយៈពេលដូចមានចែងក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ២០០.០០០(ពីររយពាន់)រៀលក្នុងមួយថ្ងៃ។

**មាត្រា៩._**

គណនេយ្យករជានីតិបុគ្គល ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ចំពោះបទល្មើសដូចខាងក្រោម÷

១- ការយឺតយ៉ាវក្នុងការបង់កម្រៃអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យប្រចាំឆ្នាំ តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ម្ចាស់អាជ្ញាបណ្ណត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់៣០០.០០០(បីរយពាន់)រៀលក្នុងមួយថ្ងៃ។

២- ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៣០០.០០០(បីរយពាន់)រៀលក្នុងមួយថ្ងៃ។

៣- យឺតយ៉ាវក្នុងការផ្តល់របាយការណ៍អំពីបុគ្គលិកមក **ន.គ.ស.** តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវរងពិន័យន្តរការណ៍ជាប្រាក់ ១០០.០០០(មួយរយពាន់)រៀលក្នុងមួយថ្ងៃ។

៤- យឺតយ៉ាវក្នុងការផ្តល់របាយការណ៍ស្ថិតិលម្អិតនៃអតិថិជន និងរបាយការណ៍ផ្សេងទៀតប្រចាំឆមាសនិងប្រចាំឆ្នាំមក **ន.គ.ស.** តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន តាមទម្រង់និងសេចក្តីណែនាំរបស់ **ន.គ.ស** ត្រូវរងពិន័យន្តរការណ៍ជាប្រាក់ ១០០.០០០(មួយរយពាន់)រៀលក្នុងមួយថ្ងៃ។

៥- យឺតយ៉ាវក្នុងការជូនដំណឹងមក **ន.គ.ស.** តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ក្រោយពីមានការផ្លាស់ប្តូរលក្ខន្តិកៈក្រុមហ៊ុន អាសយដ្ឋាន លេខទូរស័ព្ទ អ៊ីម៉ែល ត្រូវរងពិន័យអន្តរការណ៍ជាប្រាក់ ១០០.០០០(មួយរយពាន់)រៀលក្នុងមួយថ្ងៃ។

៦- ការមិនបានសុំគោលការណ៍អនុញ្ញាតជាមុនពី **ន.គ.ស.** លើការផ្លាស់ប្តូរព័ត៌មានក្រុមហ៊ុន ដែលប៉ះពាល់ដល់នីតិសម្បទានៃការប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ត្រូវទទួលរងពិន័យន្តរការណ៍ជាប្រាក់ ១.០០០.០០០ (មួយលាន)រៀល។

៧- ការផ្តល់សេវាជម្រះបញ្ជីដោយមិនបានបំពេញលក្ខខណ្ឌអនុលោមតាមបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន)រៀល។

៨- ការមិនរក្សាទុកនូវបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសដែលវិលាយស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន)រៀល។

៩- ការមិនបានអនុវត្តផែនការបណ្តុះបណ្តាលបុគ្គលិកខ្មែរ ស្របតាមផែនការដាក់មក **ន.គ.ស.** ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៥.០០០.០០០ (ប្រាំលាន)រៀល។

**មាត្រា១០.-**

ចំពោះសវនករជារូបវន្តបុគ្គល ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ចំពោះបទល្មើសដូចខាងក្រោម÷

១- ការប្រព្រឹត្តល្មើសទៅនឹងកថាខណ្ឌទី២ នៃមាត្រា២៨ នៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៤០.០០០.០០០ (សែសិបលាន)រៀល។

២- ការយឺតយ៉ាវក្នុងការបង់កម្រៃអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មប្រចាំឆ្នាំ តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៤០០.០០០(បួនរយពាន់)រៀលក្នុងមួយថ្ងៃ។

៣- ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៤០០.០០០(បួនរយពាន់)រៀលក្នុងមួយថ្ងៃ។

៤- ការមិនមានវត្តមានរបស់សវនករជាជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា តិចជាងរយៈពេលដូចមានចែងក្នុងបទប្បញ្ញត្តិជាធរមានត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់២០០.០០០(ពីររយពាន់)រៀលក្នុងមួយថ្ងៃ។

៥- ការមិនចារឹកឈ្មោះ និងហត្ថលេខារបស់សវនករជារូបវន្តបុគ្គលលើរបាយការណ៍សវនកម្មឯករាជ្យ ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន)រៀលក្នុងមួយរបាយការណ៍។

**មាត្រា១១.-**

ចំពោះសវនករជានីតិបុគ្គល ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ចំពោះបទល្មើសដូចខាងក្រោម÷

១- ការយឺតយ៉ាវក្នុងការបង់កម្រៃអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មប្រចាំឆ្នាំ តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ម្ចាស់អាជ្ញាបណ្ណត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៥០០.០០០(ប្រាំរយពាន់)រៀលក្នុងមួយថ្ងៃ។

២- ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៥០០.០០០(ប្រាំរយពាន់)រៀលក្នុងមួយថ្ងៃ។

៣- ការប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិគណនេយ្យនិងសវនកម្ម ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន)រៀល។

៤- យឺតយ៉ាវក្នុងការផ្ដល់របាយការណ៍អំពីបុគ្គលិកមក **ន.គ.ស.** តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវរងពិន័យន្តរការណ៍ជាប្រាក់ ១០០.០០០(មួយរយពាន់)រៀលក្នុងមួយថ្ងៃ។

៥- យឺតយ៉ាវក្នុងការផ្ដល់របាយការណ៍ស្ថិតិលម្អិតនៃអតិថិជន និងរបាយការណ៍ផ្សេងទៀតប្រចាំឆមាសនិងប្រចាំឆ្នាំមក **ន.គ.ស.** តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន តាមទម្រង់និងសេចក្ដីណែនាំរបស់ **ន.គ.ស** ត្រូវរងពិន័យន្តរការណ៍ជាប្រាក់ ១០០.០០០(មួយរយពាន់)រៀលក្នុងមួយថ្ងៃ។

៦- យឺតយ៉ាវក្នុងការជូនដំណឹងមក **ន.គ.ស.** តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ក្រោយពីមានការផ្លាស់ប្ដូរលក្ខន្តិកៈក្រុមហ៊ុន អាសយដ្ឋាន លេខទូរស័ព្ទ អ៊ីម៉ែល ត្រូវរងពិន័យអន្តរការណ៍ជាប្រាក់ ១០០.០០០(មួយរយពាន់)រៀលក្នុងមួយថ្ងៃ។

៧- យឺតយ៉ាវក្នុងផ្ដល់របាយការណ៍តម្លាភាពប្រចាំឆ្នាំ ចំពោះសហគ្រាសទទួលខុសត្រូវជាសាធារណៈមក **ន.គ.ស.** តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវរងពិន័យន្តរការណ៍ជាប្រាក់ ១០០.០០០(មួយរយពាន់)រៀលក្នុងមួយថ្ងៃ។

៨- ការមិនបានសុំគោលការណ៍អនុញ្ញាតជាមុនពី **ន.គ.ស.** លើការផ្លាស់ប្ដូរព័ត៌មានក្រុមហ៊ុន ដែលប៉ះពាល់ដល់នីតិសម្បទានៃការប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ត្រូវរងពិន័យន្តរការណ៍ជាប្រាក់ ១.០០០.០០០(មួយលាន)រៀល។

៩- ការផ្ដល់សេវាជម្រះបញ្ជីដោយមិនបានបំពេញលក្ខខណ្ឌអនុលោមតាមបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន)រៀល។

១០- ការមិនរក្សាទុកនូវបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសដែលរំលាយស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ត្រូវរងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន)រៀល។

១១- ការមិនបានអនុវត្តផែនការបណ្ដុះបណ្ដាលបុគ្គលិកខ្មែរ ស្របតាមផែនការដាក់មក **ន.គ.ស.** ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៥.០០០.០០០ (ប្រាំលាន)រៀល។

១២- ការផ្ដល់សេវាសវនកម្មជូនសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដោយមិនស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា១៥ នៃច្បាប់ស្ដីពីគណនេយ្យនិងសវនកម្ម ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៤០.០០០.០០០ (សែសិបលាន)រៀល។

១៣- ការមិនប្ដូរវេនសវនករជារូបវន្តបុគ្គលលើសពីរយៈពេល៥ឆ្នាំជាប់ៗគ្នា ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៤០.០០០.០០០ (សែសិបលាន)រៀល។

១៤- ការផ្ដល់សេវាសវនកម្មជូនសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដោយមិនស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងកថាខណ្ឌទី៣ នៃមាត្រា១៥ នៃច្បាប់ស្ដីពីគណនេយ្យនិងសវនកម្ម ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៤០.០០០.០០០ (សែសិបលាន)រៀល។

១៥- គុណភាពនៃការផ្ដល់សេវាសវនកម្ម និង/ ឬ សេវាការអះអាង ធ្លាក់ចុះក្នុងកម្រិតធម្មតា នឹងត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ២០.០០០.០០០ (ម្ភៃលាន)រៀល។

១៦- គុណភាពនៃការផ្ដល់សេវាសវនកម្ម និង/ ឬ សេវាការអះអាង ធ្លាក់ចុះក្នុងកម្រិតធ្ងន់ធ្ងរ នឹងត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ៤០.០០០.០០០ (សែសិបលាន)រៀល។

**មាត្រា១២.–**

លក្ខខណ្ឌ និងវិធីសាស្ត្រវាយតម្លៃលើកម្រិតនៃការធ្លាក់ចុះគុណភាពសវនកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## ជំពូកទី៣

## ស្ថាប័នមានសមត្ថកិច្ច យន្តការនៃការពិន័យអន្តរការណ៍ និងការគ្រប់គ្រងប្រាក់ពិន័យ

### ផ្នែកទី១

### ស្ថាប័នមានសមត្ថកិច្ច

**មាត្រា១៣.–**

ការអនុវត្តពិន័យអន្តរការណ៍ចំពោះបទល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ជាសមត្ថកិច្ចរបស់ **ន.គ.ស.**។

អគ្គនាយកនៃ **ន.គ.ស.** មានសិទ្ធិសម្រេចអំពីការពិន័យអន្តរការណ៍ និងវិធានការពាក់ព័ន្ធផ្សេងទៀត អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៤.–**

អគ្គនាយកនៃ **ន.គ.ស.** មានសិទ្ធិចាត់ចែងឱ្យមានការត្រួតពិនិត្យលើឯកសារ និងចាត់តាំងមន្ត្រីចុះត្រួតពិនិត្យដល់ទីតាំងរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យអនុលោមភាពនៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងលិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន។

**មាត្រា១៥.–**

អគ្គនាយកនៃ **ន.គ.ស.** មានសិទ្ធិចាត់ចែងឱ្យមានការត្រួតពិនិត្យលើឯកសារ និងចាត់តាំងមន្ត្រីចុះត្រួតពិនិត្យដល់ទីតាំងរបស់ក្រុមហ៊ុនគណនេយ្យនិង/ឬក្រុមហ៊ុនសវនកម្ម ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យអនុលោមភាពនៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងលិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន ការត្រួតពិនិត្យគុណភាពសវនកម្ម ការត្រួតពិនិត្យក្នុងក្របខណ្ឌនៃការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម និងការត្រួតពិនិត្យករណីមានបណ្តឹងបរិហារក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារនិងភារកិច្ចរបស់ខ្លួន ក្នុងនាមជាអ្នកសម្របសម្រួល។

**មាត្រា១៦.–**

មន្ត្រីមានសមត្ថកិច្ចរបស់ **ន.គ.ស.** ត្រូវគោរពក្រមសីលធម៌របស់មន្ត្រី ដែលនឹងកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

មន្ត្រីមានសមត្ថកិច្ចរបស់ **ន.គ.ស.** ដែលមានចេតនាបិទបាំងអំពើល្មើសរបស់បុគ្គលល្មើស ត្រូវទទួលទណ្ឌកម្មវិន័យរដ្ឋបាល ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

### ផ្នែកទី២

### យន្តការនៃការពិន័យអន្តរការណ៍ និងការគ្រប់គ្រងប្រាក់ពិន័យ

**មាត្រា១៧.–**

ការពិន័យអន្តរការណ៍ចំពោះសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវអនុវត្តដូចខាងក្រោម÷

១- ត្រូវបានចាត់ទុកថាយឺតយ៉ាវ ក្នុងករណីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលដាក់បញ្ជូនមក **ន.គ.ស.** ហួសពីរយៈពេលកំណត់។ ករណីនេះការគណនាប្រាក់ពិន័យត្រូវផ្អែកតាមចំនួនថ្ងៃដែលយឺតយ៉ាវ ដោយគិតចាប់ពីថ្ងៃ

ផុតកំណត់នៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ថ្ងៃដែល **ន.គ.ស.** បានទទួលសំណើជាផ្លូវការដោយភ្ជាប់ជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុដែលរៀបចំរួច។ ក្នុងលក្ខខណ្ឌនេះសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវទទួលរងពិន័យអន្តរការណ៍ដូចមានចែងក្នុងចំណុចទី១ នៃមាត្រា៤ ឬមាត្រា៥ ឬមាត្រា៦ ឬមាត្រា៧ នៃអនុក្រឹត្យនេះ។

២- ត្រូវអនុវត្តពិន័យអន្តរការណ៍ចំពោះបទល្មើសមួយ ឬច្រើនដូចមានចែងក្នុងមាត្រា៤ មាត្រា៥ មាត្រា៦ និងមាត្រា៧ វៀរលែងចំណុចទី១ នៃមាត្រាទាំងនេះ ក្រោយការរកឃើញរបស់ **ន.គ.ស.** តាមរយៈការត្រួតពិនិត្យជាក់ស្តែងនៅទីតាំងរបស់សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ **ន.គ.ស.** ឬតាមមធ្យោបាយផ្សេងទៀត។

៣- ការត្រួតពិនិត្យអនុលោមភាពរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលបានបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.** ត្រូវអនុវត្តដូចខាងក្រោម÷

៣.១. ករណីរកឃើញបទល្មើសក្នុងការត្រួតពិនិត្យលើកទី១ ត្រូវបានផ្តល់ការអនុគ្រោះលើការពិន័យចំពោះបទល្មើសនីមួយៗ

៣.២. ករណីរកឃើញបទល្មើសក្នុងការត្រួតពិនិត្យលើកទី២ ត្រូវបានពិន័យអន្តរការណ៍៤០%នៃទឹកប្រាក់ពិន័យចំពោះបទល្មើសនីមួយៗ

៣.៣. ករណីរកឃើញបទល្មើសក្នុងការត្រួតពិនិត្យលើកទី៣ ត្រូវបានពិន័យអន្តរការណ៍៨០%នៃទឹកប្រាក់ពិន័យចំពោះអំពើល្មើសនីមួយៗ។

៤- ការត្រួតពិនិត្យអនុលោមភាពរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលមិនបានបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.** ត្រូវអនុវត្តដូចខាងក្រោម÷

៤.១. ករណីរកឃើញបទល្មើសក្នុងការត្រួតពិនិត្យលើកទី១ ត្រូវបានពិន័យអន្តរការណ៍៥០%នៃទឹកប្រាក់ពិន័យចំពោះអំពើល្មើសនីមួយៗ

៤.២. ករណីរកឃើញបទល្មើសក្នុងការត្រួតពិនិត្យលើកទី២ ត្រូវបានពិន័យអន្តរការណ៍១០០%នៃទឹកប្រាក់ពិន័យចំពោះអំពើល្មើសនីមួយៗ។

**មាត្រា១៨.-**

ការពិន័យអន្តរការណ៍ចំពោះគណនេយ្យករ និងសវនករត្រូវអនុវត្តដូចខាងក្រោម÷

១- ករណីគណនេយ្យករ និងសវនករបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងចំណុចទី២ដល់ទី៤ នៃមាត្រា៨ ចំណុចទី១ដល់ទី៦ និងទី១២ នៃមាត្រា៩ ចំណុចទី២ដល់ទី៤ នៃមាត្រា១០ ចំណុចទី១ដល់ទី៧ ចំណុចទី១៣ ទី១៦ និងទី១៧ នៃមាត្រា១១ នៃអនុក្រឹត្យនេះ **ន.គ.ស.** ត្រូវចេញលិខិតពិន័យ ដោយពុំចាំបាច់ធ្វើការចុះត្រួតពិនិត្យជាមុនឡើយ។

២- ការអនុវត្តចំពោះបទល្មើសដូចមានចែងក្នុងចំណុចទី១ នៃមាត្រា៨ ចំណុចទី៧ដល់ទី១១ នៃមាត្រា៩ ចំណុចទី១នៃមាត្រា១០ ចំណុចទី៨ដល់ទី១២ ចំណុចទី១៤ និងទី១៥ នៃមាត្រា១១ នៃអនុក្រឹត្យនេះ ត្រូវធ្វើឡើងដោយឆ្លងកាត់ការត្រួតពិនិត្យដល់ទីកន្លែង ឬតាមរយៈមធ្យោបាយជាក់លាក់ផ្សេងទៀតជាមុន។

**មាត្រា១៩.-**

បែបបទនិងនីតិវិធីនៃការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ដែលបានមកពីការពិន័យដូចដែលបានកំណត់នៅក្នុងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**មាត្រា២០.-**

ក្នុងករណីបុគ្គលល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ អគ្គនាយកនៃ **ន.គ.ស.** អាចអនុវត្តវិធានការមួយ ឬច្រើនដូចខាងក្រោម÷

- អញ្ជើញម្ចាស់សហគ្រាស ឬប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ តាមលិខិតលាយលក្ខណ៍អក្សរ ឬតាមគ្រប់មធ្យោបាយជាក់លាក់ផ្សេងទៀត ដោយទុករយៈពេល៣០(សាមសិប)ថ្ងៃឱ្យចូលខ្លួនមកបំភ្លឺ និង/ឬបំពេញកាតព្វកិច្ច
- ស្នើទៅក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីមានវិធានការស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។ ក្នុងករណីនេះ ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវផ្តល់កិច្ចសហការជាមួយ **ន.គ.ស.** ក្នុងការបំពេញមុខងារ និងភារកិច្ចឱ្យមានប្រសិទ្ធភាពខ្ពស់ និង/ឬកសាងសំណុំរឿងបញ្ជូនទៅតុលាការ ឬអយ្យការអមសាលាជម្រះក្តី។

## ផ្នែកទី៣

## យន្តការនៃការត្រួតពិនិត្យកាតព្វកិច្ចគណនេយ្យនិងសវនកម្មរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលមានហានិភ័យ

**មាត្រា២១.-**

ការត្រួតពិនិត្យកាតព្វកិច្ចគណនេយ្យនិងសវនកម្មរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលមានហានិភ័យត្រូវធ្វើឡើងដោយផ្អែកលើស្ថានភាពដូចខាងក្រោម÷

១- សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលមិនបានដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.**

២- សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលទទួលបានមតិពីសវនកររងករាជ្យថាមិនត្រឹមត្រូវ ឬមតិបដិសេធ

៣- សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលទទួលរងបណ្តឹង

៤- សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញដែល **ន.គ.ស.** បានធ្វើការត្រួតពិនិត្យ និងវាយតម្លៃកម្រិតអនុលោមភាពរួច ពុំបានកែលម្អកំហុសបន្ទាប់ពីបានរកឃើញ

៥- សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលរាជរដ្ឋាភិបាលបានចាត់ទុកថាមានហានិភ័យ ដែលកំណត់ដោយរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២២.-**

បែបបទ និងនីតិវិធីនៃការត្រួតពិនិត្យកាតព្វកិច្ចគណនេយ្យនិងសវនកម្មរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## ជំពូកទី៤
## ការមិនបង់ប្រាក់ពិន័យអន្តរការណ៍ និងបណ្តឹងតវ៉ា

**មាត្រា២៣.-**

ក្នុងករណីបុគ្គលល្មើសមិនបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវដំឡើងជាពីរដង។ ករណីខកខានលើសពី៦០(ហុកសិប)ថ្ងៃ ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នេះនឹងត្រូវដំឡើងជាបីដង។ ករណីផុតរយៈពេល៩០(កៅសិប)ថ្ងៃ **ន.គ.ស.** នឹងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

រយៈពេល៣០(សាមសិប)ថ្ងៃ ៦០(ហុកសិប)ថ្ងៃ និង៩០(កៅសិប)ថ្ងៃខាងលើនេះ គិតចាប់ពីថ្ងៃបុគ្គលល្មើសបានទទួលលិខិតជូនដំណឹងផ្លូវការអំពីការបង់ប្រាក់ពិន័យអន្តរការណ៍ពី **ន.គ.ស.**។

**មាត្រា២៤.-**

ប្រសិនបើបុគ្គលទទួលរងពិន័យមិនសុខចិត្តនឹងការសម្រេចពិន័យអន្តការណ៍ ដែលចេញដោយអគ្គនាយកនៃ **ន.គ.ស.** បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ាទៅអគ្គនាយកនៃ **ន.គ.ស.** ដោយត្រូវបញ្ជាក់អំពីហេតុផល។

ក្នុងករណីដែលបុគ្គលទទួលរងពិន័យនៅតែមិនសុខចិត្តនឹងការសម្រេចលើការតវ៉ាដូចមានចែងក្នុងកថាខណ្ឌខាងលើ បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ។

ក្នុងករណីបុគ្គលទទួលរងពិន័យនៅតែមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បុគ្គលនោះអាចប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ច។

ការគណនារយៈពេលសម្រាប់ទុកសិទ្ធិឱ្យប្តឹងតវ៉ាដូចមានចែងក្នុងប្រការនេះ គឺគិតចាប់ពីថ្ងៃបុគ្គលដែលត្រូវទទួលរងពិន័យបានទទួលលិខិតជូនដំណឹងពី **ន.គ.ស.** (ឬទទួលបានដំណឹងជាក់លាក់និងត្រឹមត្រូវពី **ន.គ.ស.**) អំពីការសម្រេច។

បណ្តឹងរបស់បុគ្គលដែលទទួលរងពិន័យអន្តការណ៍ទៅតុលាការ ពុំមានអនុភាពផ្អាកការអនុវត្តសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារឡើយ។

**មាត្រា២៥.-**

វិធាន និងនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយបណ្តឹងតវ៉ាចំពោះការសម្រេចពិន័យអន្តរការណ៍ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា២៦.-**

បទប្បញ្ញត្តិដែលកំពុងស្ថិតនៅជាធរមានទាំងឡាយណាដែលត្រូវបានដាក់ចេញដោយផ្អែកតាមអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ត្រូវបន្តមានអានុភាពអនុវត្តរហូតដល់មានការកំណត់ផ្សេងពីនេះ។

## **ជំពូកទី៦**
## **អវសានប្បញ្ញត្តិ**

**មាត្រា២៧._**

អនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៨._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ខែ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

***<u>កន្លែងទទួល÷</u>***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ